# វេទិកាវៀនសូត្រស្តីពីការគ្រប់គ្រងជនជាមនុស្សលើកាទី ៤៦

ក្រោមប្រធានបទ **របប**

**សន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ**

*ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២២*

*ម៉ោង ៨:៣០ ដល់ ១២:០០ ថ្ងៃត្រង់*

*តាមរយៈការចូលរួមផ្ទាល់* ទីតាំងមជ្ឈមណ្ឌលដាយកូនៀ

## ១. សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពដ៏ធំ និងមានវ័យចំណាស់ជាងគេមួយនៅក្នុងប្រទេសកម្ពុជា។ រហូតមកដល់ខែ កុម្ភៈ ឆ្នាំ២០២២ អង្គការ គ.ស.ក មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួន ១៨៥។ បច្ចុប្បន្ននេះ អង្គការ គ.ស.ក បានកំពុងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ចដំណាក់កាលទី៤ ពីឆ្នាំ២០២១ ដល់ ២០២៣។ កម្មវិធីនេះ មានគោលបំណងសំខាន់ចំនួនពីរ៖ ទី១ គឺធ្វើឲ្យប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល និងទី២ មជ្ឈមណ្ឌលធនធានប្រកបដោយនិរន្តរភាព សម្រាប់អង្គការសង្គមស៊ីវិលទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។

នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ថ្មីៗនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញប្រកាសអន្តរក្រសួង (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីកំណត់ថ្ងៃនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។ យ៉ាងណាមិញ អង្គការក្នុងស្រុក និងអង្គការបរទេសដែលកំពុងប្រតិបត្តិការងារនៅក្នុងប្រទេសកម្ពុជា នៅពុំទាន់យល់ដឹងស៊ីជម្រៅអំពីខ្លឹមសារប្រកាសអន្តរក្រសួងនៅឡើយទេ។

ដូចនេះ ដើម្បីឱ្យអង្គការសង្គមស៊ីវិលអាចមានលទ្ធភាពគ្រប់គ្រាន់អនុលោមតាមសេចក្តីប្រកាសនេះ និងពិសេសមានឱកាសចែករំលែកបទពិសោធន៍ និងមេរៀនល្អៗ អង្គការ គ.ស.ក នឹងរៀបចំវេទិកាវៀនសូត្រស្តីពី របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។ វេទិកានេះ នឹងប្រព្រឹត្តឡើងនា**ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលដាយកូនៀ អាសយដ្ឋានផ្ទះលេខ ១៩ ផ្លូវ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។**

## ២. គោលបំណងនៃវេទិការៀនសូត្រ

1. ចូលរួមផ្សព្វផ្សាយប្រកាសអន្តរក្រសួងស្តីពី ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជូនដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។
2. បង្កើនការយល់ដឹង និងអនុលោមភាពតាមសេចក្តីប្រកាសអន្តរក្រសួងខាងលើ។
3. ពង្រីកទំនាក់ទំនងក្នុងចំណោមអ្នកកាន់តួនាទីគ្រប់គ្រងធនធានមនុស្ស។

## ៣. អ្នកចូលរួម និងការកំណត់តម្លៃនៃការចូលរួមក្នុងវេទិការៀនសូត្រ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស ដែលអញ្ជើញមកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។

- **ការចូលរួមដោយផ្ទាល់**
  - **ផ្តល់ជូនសម្រាប់តែអង្គការសមាជិក របស់ អង្គការ គ.ស.ក តែប៉ុណ្ណោះ**
  - **ផ្តល់ជូន ០២ កន្លែង សម្រាប់អង្គការសមាជិកនីមួយៗ**
  - **បើមានអង្គការសមាជិករបស់ អង្គការ គ.ស.ក មកលើស (ចាប់ពីអ្នកទី៣ទៅគឺ២៥USD/ម្នាក់ ក្នុងករណីចូលផ្ទាល់)**
  - **ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនមែនជាសមាជិកអង្គការ គ.ស.ក ចង់ចូលរួមដោយផ្ទាល់ត្រូវបង់ថ្លៃ ៥០ដុល្លារក្នុងម្នាក់/វគ្គ។**

**សម្គាល់៖** ចំនួនមានកំណត់ សូមចុះឈ្មោះជាមុនតាមរយៈតំណរចុះឈ្មោះដែលបានផ្តល់ជូន។

## ៤. របៀបចុះឈ្មោះ

អ្នកចូលរួមទាំងអស់តម្រូវឲ្យចុះឈ្មោះជាមុន សម្រាប់ការអញ្ជើញចូលរួមដោយផ្ទាល់នេះ។

## ៥. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៧:៤០ -០៨:១៥ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ០៨:១៥-០៨:៣០ | - ការណែនាំពី បទបញ្ជាផ្ទៃក្នុងសម្រាប់វេទិការៀនសូត្រ<br>- គោរពភ្លេងជាតិ<br>- ប្រកាសគោលបំណងវេទិការៀនសូត្រ | **អ្នករៀបចំកម្មវិធី**<br>អង្គការ គ.ស.ក |
| ០៨:៣០-៨:៤០ | កិច្ចស្វាគមន៍ និងបើកកម្មវិធីដោយតំណាងអង្គការ គ.ស.ក | **អ្នកស្រី ស៊ិន ពុទ្ធារី**<br>នាយិកប្រតិបត្តិអង្គការគ.ស.ក |

| | | |
|---|---|---|
| ៨:៤០ -៨:៤៥ | ការថតរូបជុំគ្នា | |
| ៨:៤៥ -១០:១៥ | បទបង្ហាញស្តីពីៈ  របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។<br>• លក្ខខណ្ឌ និងតាវកាលិក សោធនជរាភាព<br>• លក្ខខណ្ឌ និងតាវកាលិក វិភាជន៍ជរាភាព<br>• លក្ខខណ្ឌ និងតាវកាលិក សោធនទុព្វលភាព<br>• សោធនឧត្តរជីវី | **សម្របសម្រួលដោយៈ** មន្ត្រីជំនាញបេឡាជាតិរបបសន្តិសុខសង្គម |
| ១០:១៥ -១០:៣០ | សម្រាកអាហារសម្រន់ | |
| ១០:៣០-១១:០០ | បទបង្ហាញស្តីពីៈ  របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។<br>• លក្ខខណ្ឌ និងតាវកាលិក សោធនជរាភាព<br>• លក្ខខណ្ឌ និងតាវកាលិក វិភាជន៍ជរាភាព<br>• លក្ខខណ្ឌ និងតាវកាលិក សោធនទុព្វលភាព<br>• សោធនឧត្តរជីវី | **សម្របសម្រួលដោយៈ** មន្ត្រីជំនាញបេឡាជាតិរបបសន្តិសុខសង្គម |
| ១១:០០-១១:៥០ | **សំណួរនិងចម្លើយ** | **សម្របសម្រួលដោយៈ** **លោក ជា ទិបុល** អ្នកគ្រប់គ្រងផ្នែកអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ |
| ១១:៥០-១២:០០ | បិទកម្មវិធី | **នឹងជម្រាបពេលក្រោយ** |
| ១២:០០-១៣:៣០ | ពិសារអាហារថ្ងៃត្រង់រួមគ្នា | |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។ អង្គការ គសក នឹងយករូបថតនៃវេទិការៀនសូត្រនេះសម្រាប់ការប្រើប្រាស់ផ្លូវការផ្សេងៗ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់* *raingsey.roeung@ccc-cambodia.org*